ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១២២/១០-ម៉េង យ៉ាន់**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **ទូន ស៊ីផាន់**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ម៉េង យ៉ាន់ ហ្គាមេន មេនញូហ្វាក់ធូរី & វ៉េត ប្រូសេសស៊ីង អិលធីឌី**

អាសយដ្ឋាន : ភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០៨៨ ៨ ៩៩៩ ៩៥៥ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោក ឡាយ សំអួន | ប្រធានរដ្ឋបាល |
| ២- លោក លី វិចិត្រ | ផ្នែកធនធានមនុស្ស |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ : **- សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា**

**- សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ម៉េង យ៉ាន់**

អាសយដ្ឋាន : ភូមិលេខ៣ ឃុំស្វាយរលំ ស្រុកស្អាង ខេត្តកណ្តាល

លេខទូរស័ព្ទ : ០១២ ៩៨៨ ៦២៣ ទូរសារ : គ្មាន

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh ◈ Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org ◈ Website: www.arbitrationcouncil.org

តំណាងកម្មករនិយោជិតៈ

| | |
|---|---|
| ១- លោក មូ ឈាង | មន្ត្រីដោះស្រាយវិវាទនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោក សំ រតនា | មន្ត្រីដោះស្រាយវិវាទនៃសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣- លោក ងឹម ទិន | ប្រធានសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ម៉េង យ៉ាន់ |
| ៤- លោក ជេត ម៉ាន់ | ទីប្រឹក្សាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ម៉េង យ៉ាន់ |
| ៥- លោក ហុង ហ៊ីង | ហិរញ្ញិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃក្រុមហ៊ុន ម៉េង យ៉ាន់ |
| ៦- លោក ឃឹម ចំរុង | សកម្មជនសហជីព |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ក្រុមហ៊ុនពុំឯកភាពទទួលយកថ្នាក់ដឹកនាំ និងសកម្មជនសហជីព CCAWDU ទាំង ៦ នាក់ ចូលធ្វើការវិញទេ ពីព្រោះពួកគាត់ទាំង ៦ នាក់ នេះ ជាកិច្ចសន្យាការងារមានថិរវេលាកំណត់ ហើយក្រុមហ៊ុនពុំមានលទ្ធភាពបន្តទេ។

២- ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ប្រាក់ឈ្នួលរំលឹកការងារជូនដល់ពួកគាត់ទេ ពីព្រោះ

-ក្រុមហ៊ុនពុំមានការងារផ្តល់ជូនពួកគាត់ធ្វើ

-ពួកគាត់បានប្រព្រឹត្តខុសនឹងមាត្រា៦៩ និងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ស្របតាមច្បាប់ស្តីពីការងារ

៣- ក្រុមហ៊ុនមិនមានចេតនា រើសអើង ធ្វើទុក្ខបុកម្នេញមកលើថ្នាក់ដឹកនាំ សកម្មជន និងសមាជិកសហជីព CCADUW ទេ ពីព្រោះក្រុមហ៊ុនមានសហជីពពីររួចមកហើយ គឺសហជីពសម្លេងយុវជនខ្មែរ និងសហជីពខ្មែរមានភាពជាតំណាងបំផុតក្នុងក្រុមហ៊ុន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ

នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩០ កប/ប្រក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ (អាណត្តិទី៧) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៦២៩/១០ កប/កណ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១០ (វេលាម៉ោង ០៨:០០ នាទី ព្រឹក) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលបណ្តឹងពីសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ម៉េង យ៉ាន់ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះ ជាបន្តបន្ទាប់ និងផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ដោយបានទទួលលទ្ធផលមិនសះជាចំនួន ០៣ ចំណុច លើការទាមទារទាំងអស់ចំនួន ០៣ ចំណុច ។ ចំណុចមិនសះជាចំនួន ០៣ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១០ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ០៣ ចំណុចនេះ ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ (វេលាម៉ោង ០៨:០០ នាទី ព្រឹក) ។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាលើចំណុចវិវាទទាំង ០៣ ចំណុចនេះដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានឯកភាពបញ្ចូលចំណុចវិវាទទាំង ០៣ ចូលគ្នាតែមួយ ព្រោះថា ចំណុចវិវាទទាំងបីជាចំណុចទាក់ទងគ្នាតែមួយ ។ ដូច្នេះ នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាចំណុចមិនសះជាទាំង ០៣ រួមបញ្ចូលគ្នាតែមួយចំណុច ដោយផ្អែកលើភស្តុតាង និង ហេតុផល ដូចខាងក្រោម:

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតរបស់ក្រុមហ៊ុន ម៉េង យ៉ាន់ ហ្គាមេន គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើរសុំលើកពេលសវនាការ (សំណុំរឿងលេខ ១២២/១០) ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០។

២- សារណាឆ្លើយការពារនៃវិវាទការងារក្នុងសំណុំរឿងលេខ ៥២២/១០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០។

៣- លិខិតសុំលាលែងពីសហជីពរបស់ឈ្មោះ គាង ហ៊ាង ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០។

៤- លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន ម៉េង យ៉ាន់ ប្រគល់សិទ្ធិជូន លោក ឡាយ សំអូន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០។

៥- លិខិតរបស់ ប្រធាននាយកដ្ឋានវិវាទការងារ លេខ ៨៥៤ កប/អក/វក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ជំរាបមកលោក ងឹម ទិន ស្តីពីការស្នើសុំចុះបញ្ជីការសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ម៉េង យ៉ាន់ ហ្គាមេន។

៦- លក្ខន្តិកៈរបស់ក្រុមហ៊ុន ម៉េង យ៉ាន់ ហ្គាមេន ចុះបញ្ជីលេខ ៧៣៧/០៦ ពណ.នតក.បព ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០០៦។

៧- លិខិតរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម លេខ ១៣៩៧ ពណ.នតក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីក្រុមហ៊ុនវិនិយោគទុនឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់។

៨- ប័ណ្ណប៉ាតង់ របស់ក្រុមហ៊ុន ម៉េង យ៉ាន់ ហ្គាមេន លេខ ៤៧.២០១០ សពដ.កណ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០។

៩- វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ម៉េង យ៉ាន់ ហ្គាមេន លេខ ១៣៣៣ ពណ.ចបព ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩។

១០- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម របស់ក្រុមហ៊ុន ម៉េង យ៉ាន់ ហ្គាមេន លេខ ៤១៧ ព.ដ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧។

១១- លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៏កម្ពុជា លេខ ៣២៦៨/០៦ គ.វ.ក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៦ ជំរាបមក លោកប្រធានក្រុមហ៊ុន ម៉េង យ៉ាន់ ហ្គាមេន ស្តីពីករណីសំណើសុំវិនិយោគ

លើគំរោងបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ និង បោកគក់។

១២- លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខ ១៩៥៧/០៦ គ.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ ២០០៦ ជំរាបមក លោក Wong Mang Chun Cary ជនជាតិចិន "ហុងកុង" ស្តីពីករណីសំណើ ស៊ីវិនិយោគ លើគំរោងបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ និង បោកគក់។

១៣- កាត. លិខិតជូនដំណឹងបញ្ចប់កិច្ចសន្យា និងកិច្ចសន្យាការងារ របស់ឈ្មោះ អេង ជឿន. សំ ពៅ. កាន ឡូត. វ៉ែន ចាន់. ហៀង សារុំ. អ៊ុំ ណាត. ខន ចិត្រា. ដុស ឡុង. ឃឹម សារ៉ាក់. ប៊ិន សុផាត. រឿន ពៅ. សុខ សំអាត. ស៊ន ចាន់ថុល. យ៉ឹង យ៉ាត់. ឃន់ សុឃា. អ៊ុក គាកុសល្យ. ដុស លាប. អាត វិត. សោ ភានិត. មួយ រី. ផាត គីមលាង. ផាត កយ. កែវ រីមណា. ចន្ទ ចិត្រា. ហ៊ូ គីមហុង. ឌុង សុខជន. ជួន ស្រី។

១៤- កាត. លិខិតជូនដំណឹងបញ្ចប់កិច្ចសន្យា និងកិច្ចសន្យាការងារការងារបណ្តោះអាសន្នរបស់ឈ្មោះ ឆេង សុខជា. កែវ វ៉ាន់នី. ប៊ី ណាទី។

១៥- លិខិតជូនដំណឹងបញ្ចប់កិច្ចសន្យា. កិច្ចសន្យាការងារ និងឯកសារជាភាសារបរទេស របស់ឈ្មោះ គាង ហ៊ាង. ហ៊ូ គីមហុង. ផាត កយ. ជេត ម៉ាន់. ហួត សុខ៊ូ។

១៦- សារណាឆ្លើយការពារ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៃវិវាទការងារក្នុងសំណុំរឿងលេខ ៥២២/១០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ចុះថ្ងៃទ០៣ ខែធ្នូ ឆ្នាំ២០១០។

១៧- បញ្ជីឈ្មោះអ្នកធ្វើការនៅផ្នែកខាត់សាច់។

១៨- បញ្ជីឈ្មោះអ្នកធ្វើការនៅផ្នែក អ៊ុត។

១៩- បញ្ជីឈ្មោះអ្នកឈប់សរុបសំរាប់ខែ០៨. ០៩ និង ១០ ឆ្នាំ២០១០។

២០- បញ្ជីឈ្មោះអ្នកឈប់នៅផ្នែកអ៊ុត ប្រចាំខែ៨. ៩ និង ១០ ឆ្នាំ២០១០។

២១- បញ្ជីឈ្មោះអ្នកឈប់នៅផ្នែកខាត់សាច់ ប្រចាំខែ៨. ៩ និង ១០ ឆ្នាំ២០១០។

២២- បញ្ជីឈ្មោះសមាជិកសហជីពសម្លេងយុវជនខ្មែរ ដែលក្រុមហ៊ុនបានកាត់ភាគទានជូនក្នុងខែ៦. ៧. ៨. ៩ និង១០ ឆ្នាំ២០១០។

២៣- បញ្ជីឈ្មោះសមាជិកសហជីពខ្មែរ ដែលក្រុមហ៊ុនបានកាត់ភាគទានជូនក្នុងខែ៦. ៧. ៨. ៩ និង១០ ឆ្នាំ២០១០។

២៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ម៉េង យ៉ាន់ ចុះបញ្ជិកាលេខ ៣៦៥/០៨ ក.ប.វ ចុះថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០០៨។

២៥- លិខិតលាលែងពីសហជីព។

២៦- លិខិតសំណូមពររបស់កម្មករ-កម្មការិនី ដែលបំរើការនៅក្នុងក្រុមហ៊ុន ម៉េង យ៉ាន់ គោរពជូននាយិកាក្រុមហ៊ុន ម៉េង យ៉ាន់ ស្តីពីសូមបដិសេធមិនព្រមទទួលយកបុគ្គលទាំង ១៦ រូប ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតជូនដំណឹងបើកប្រាក់ខែរបស់ឈ្មោះ ជេត ម៉ាន់ និង ហុង ហ៊ីម។

២- ពាក្យបណ្តឹងរបស់ឈ្មោះ ហួន សុខូ៊ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០។

៣- កំណត់ហេតុរបស់ឈ្មោះ ហួន សុរ៉ូ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១០។

៤- ពាក្យសុំចុះបញ្ជិកា របស់ក្រុមស្ថាបនិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ ម៉េង យ៉ាន់ ហ្គាមេន គោរពជូន ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីការសុំចុះបញ្ជិកាសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ ម៉េង យ៉ាន់ ហ្គាមេន ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០។

៥- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការជូនសារណាក្រុមហ៊ុន ម៉េង យ៉ាន់ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០។

៦- បង្កាន់ដៃទទួលសំណុំរឿង របស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានទទួលពីសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ រោងចក្រ ម៉េង យ៉ាន់ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០។

៧- លិខិតរបស់ក្រុមស្ថាបនិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរនៃរោងចក្រ ម៉េង យ៉ាន់ ហ្គាមេន សូមគោរពជូន ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងការងារ និងបណ្តុះវិជ្ជាជីវៈ ស្តីពីសុំចុំបញ្ជិកាលើសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៃរោងចក្រ ម៉េង យ៉ាន់ ហ្គាមេន ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០។

៨- លិខិតរបស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ១១៥០ សជណ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០ ស្តីពីករណីរបាយការណ៍ ស្តីពីសភាពការណ៍ និងសំណើសុំគោលការណ៍បន្តអនុវត្តអនុសាសន៍របស់សម្តេចតេជោកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០។

៩- ដីកាសម្រេចអំពីពាក្យសុំតវ៉ា ចំពោះដីកាសម្រេចរក្សាការពារ របស់ សាលាដំបូងខេត្តកណ្តាល លេខ ៣៧ ដកសរ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១០។

១០- ពាក្យបណ្តឹង និងកំណត់ហេតុ របស់ឈ្មោះ ហួន សុខូ៊, ហ៊ូ គីមហុង, ជេត ម៉ាន់ និង ហុង ហ៊ីម។

១១- ពាក្យបណ្តឹង របស់ឈ្មោះ ផាត កយ។

១២- កំណត់ហេតុរបស់ឈ្មោះ គាង ហ៊ាង។

១៣- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីការជំទាស់នឹងសារណាឆ្លើយការពាររបស់ក្រុមហ៊ុន ម៉េង យ៉ាន់ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ម៉េង យ៉ាន់ លេខ ៦២៩/១០ កប/កណ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ម៉េង យ៉ាន់ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី១ លេខ ៦៤៨ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី១ លេខ ៦៤៩ កប/អក/វក/លកអ. ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលើកទី២ លេខ ៦៧៧ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលើកទី២ លេខ ៦៧៨ កប/អក/វក/លកអ. ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- រោងចក្រ ម៉េង យ៉ាន់ ហ្គាមេន មានកម្មករនិយោជិតសរុបប្រហែល ៥០០ នាក់។
- ភាគីកម្មករនិយោជិតលើកឡើងថា សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ប្រចាំរោងចក្រ ម៉េង យ៉ាន់ ហ្គាមេន ដែលជាដើមបណ្តឹងក្នុងរឿងនេះ មានសមាជិកប្រហែល ២០០ នាក់។ ប៉ុន្តែ ក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនដឹងថា សហជីពនេះមានសមាជិកប៉ុន្មានទេ ព្រោះសហជីពគ្មានបញ្ជិកាទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមិនបានកាត់ភាគទានសហជីពទេ។

**ចំណុចវិវាទទី១ ទី២ និងទី៣ : ភាគីកម្មករនិយោជិតទាមទារ ឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិតចំនួន ៣ នាក់ ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល និងបញ្ឈប់ការរើសអើង ធ្វើទុក្ខបុកម្នេញមកលើថ្នាក់ដឹកនាំ សកម្មជន និងសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិត ៣ នាក់ ក្នុងនោះមានលោក ហុង ហ៊ឹម អត្តលេខ ៨០១១៦៨ លោក ជេត ម៉ាន់ អត្តលេខ ៨០១៩១៩ និងលោក ហួន សុខរ៉ូ អត្តលេខ ៨០១៨៨០ ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល។ ក្នុងចំណោមកម្មករនិយោជិតទាំងបីនាក់ដែលធ្វើការទាមទារក្នុងចំណុចនេះ មានតែពីរនាក់ទេ គឺលោក ហុង ហ៊ឹម និងលោក ជេត ម៉ាន់ មានវត្តមាននៅក្នុងសវនាការ។ ចំណែកឯ លោក ហួន សុខរ៉ូ អវត្តមាននៅពេលសវនាការដោយសារឈឺ មិនអាចមកចូលរួមបាន។ ភាគីសហជីពបានអះអាងថា ខ្លួនអាចតំណាងឱ្យលោក ហួន សុខរ៉ូ បាន ព្រោះគាត់ជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរដែរ។ កម្មករនិយោជិតបីនាក់ទៀត គឺឈ្មោះ ផាត កយ ឈ្មោះ ហ៊ូ គីមហុង និងឈ្មោះ គាង ហ៊ាង បានបញ្ឈប់ការទាមទារនៅក្នុងសំណុំរឿងនេះហើយ។
- ភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតលើកឡើងថា នៅក្នុងក្រុមហ៊ុនមានប្រើកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែម្តងៗ ចំនួនជាង ៩០ ភាគរយ នៃកម្មករនិយោជិតទាំងអស់។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា នៅក្នុងអំឡុងពេលនៃការបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងបីនាក់ខាងលើនេះ ក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារដែលមានថេរវេលាកំណត់ របស់កម្មករនិយោជិតទាំងអស់ចំនួន ៣៧ នាក់ ក្នុងនោះ រួមមានពួកគាត់ និងសមាជិកសហជីពផ្សេងទៀតដែរ។
- ភាគីកម្មករនិយោជិតបានលើកឡើងថា ភាគីនិយោជកមានការរើសអើងសហជីពនៅក្នុងការមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងបីរូបនេះ។ ភាគីក្រុមហ៊ុនបានជំទាស់នឹងការលើកឡើងនេះ ដោយបញ្ជាក់ថា ក្រុមហ៊ុនមិនបានរើសអើងសហជីពណាមួយនោះទេ ព្រោះក្រុមហ៊ុនអត់មានការងារធ្វើ ហើយកិច្ចសន្យាការងារពួកគាត់ដល់កាលកំណត់។ ពេលដែលក្រុមហ៊ុនមានការងារធ្វើវិញ ក្រុមហ៊ុននឹងទទួលយកចូលធ្វើការវិញ មិនថាពួកគាត់ទាំងបីនាក់ដែលទាមទារក្នុងសំណុំរឿងនេះ ឬកម្មករនិយោជិតផ្សេងទៀតដែលក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារនោះទេ។
- ភាគីក្រុមហ៊ុនបានបញ្ជាក់ថា តាំងពីពេលបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៣៧ នាក់ ក្នុងខែសីហា ឆ្នាំ២០១០ នេះមក ក្រុមហ៊ុនមិនទាន់មានរើសកម្មករនិយោជិតថ្មីចូលធ្វើការទេ

ព្រោះអត់មានការងារធ្វើ។ ភាគីកម្មករនិយោជិតបញ្ជាក់ថា ក្រុមហ៊ុនមានរើសកម្មករនិយោជិតចូលធ្វើការ ប៉ុន្តែ មិនដឹងថា ផ្នែកអ៊ុត និងផ្នែកខាត់ មានរើសចូល ឬអត់នោះទេ។

- ភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតលើកឡើងថា ការបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែចុងក្រោយ របស់លោក ហុង ហ៊ីម លោក ជេត ម៉ាន់ និងលោក ហួន សុខរ៉ូ មិនមានការជូនដំណឹងមុនពីការបញ្ចប់កិច្ចសន្យានេះទេ។
- ភាគីក្រុមហ៊ុនបញ្ជាក់ថា មូលហេតុដែលក្រុមហ៊ុនមិនជូនដំណឹងពេលបញ្ចប់កិច្ចសន្យាការងាររបស់លោក ហុង ហ៊ីម លោក ជេត ម៉ាន់ និងលោក ហួន សុខរូ ព្រោះកិច្ចសន្យាការងាររបស់ពួកគាត់ជាកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ។ ច្បាប់ស្តីពីការងារមិនតម្រូវឱ្យក្រុមហ៊ុនធ្វើការជូនដំណឹងមុន នៅពេលបញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់ ៣ ខែទេ។
- ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីសហជីពដើមបណ្តឹងមិនមានបញ្ជិកាសហជីពនោះទេ។ ផ្អែកតាមឯកសារចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១០ ដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលបានភាគីកម្មករនិយោជិតនៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ឃើញថា ការបោះឆ្នោតបង្កើតសហជីព គឺធ្វើឡើងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០ និងកាលបរិច្ឆេទនៃបង្កាន់ដៃសុំចុះបញ្ជិកា ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០។ ចំណែកឯ ឯកសារបង្កាន់ដៃទទួលសំណុំរឿងសុំចុះបញ្ជិកាសហជីពដែលនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានចេញ ហើយដែលក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលពីភាគីកម្មករនិយោជិតនៅថ្ងៃដដែលនោះ បែរជាចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១០ ទៅវិញនេះបង្ហាញឱ្យឃើញថា ការបោះឆ្នោតសហជីពបែរជាកើតឡើងនៅក្រោយការដាក់ពាក្យសុំចុះបញ្ជិកាទៅវិញ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វាជាករណីដែលមិនអាចទៅរួចទេ។ កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវតែកើតឡើងមុនពេលដាក់ពាក្យសុំចុះបញ្ជិកា។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា នៅលើបង្កាន់ដៃ ទទួលសំណុំរឿងសុំចុះបញ្ជិកាសហជីពដែលនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញនោះ មានតែឈ្មោះអ្នកទទួលតែប៉ុណ្ណោះ ប៉ុន្តែ ពុំមានហត្ថលេខារបស់ឈ្មោះអ្នកទទួលនោះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា បង្កាន់ដៃនេះ មានភាពមិនប្រក្រតី ហើយកាលបរិច្ឆេទចេញបង្កាន់ដៃនេះ មិនមានភាពស៊ីសង្វាក់ទៅនឹងភស្តុតាងផ្សេងទៀត មានដូចជាកាលបរិច្ឆេទបោះឆ្នោតជាដើម។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា បង្កាន់ដៃរបស់នាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនេះ មិនអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលយកមកពិចារណាបានទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងទទួលយកមកពិចារណាតែភស្តុតាងស៊ីសង្វាក់ដែលកម្មករនិយោជិតបាន

ដាក់ជូន ដែលមាន ៖ ១) ការបោះឆ្នោតបង្កើតសហជីព គឺធ្វើឡើងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០ និង ២) កាលបរិច្ឆេទបង្ហាន់ដៃសុំចុះបញ្ជិកា នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០។

- នៅក្នុងក្រុមហ៊ុន ម៉េង យ៉ាន់ មានសហជីពចំនួនពីរដែលកំពុងប្រតិបត្តិការ និងមានចុះបញ្ជិកាត្រឹមត្រូវនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺ សហជីពសម្លេងយុវជនខ្មែរ និងសហជីពខ្មែរ។

**<u>ករណីលោក ហុង ហ៊ីម ៖</u>**

- ភាគីកម្មករនិយោជិតបានលើកឡើងថា លោក ហុង ហ៊ីម ចូលធ្វើការដំបូងថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ មានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែម្តង១។ លោកធ្វើការនៅផ្នែកអ៊ុត ជាកម្មករនិយោជិតធម្មតា ទទួលបានប្រាក់ខែគោល ៥០ ដុល្លារអាមេរិក ក្នុងមួយខែ ហើយប្រាក់ឈ្នួលសរុបជាមធ្យមទទួលបាន ពី ៨០ ទៅ ១០០ ដុល្លារអាមេរិក ក្នុងមួយខែ។ លោកត្រូវបានក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ចុងក្រោយនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។ ភាគីក្រុមហ៊ុនមិនជំទាស់នឹងការលើកឡើងនេះទេ។
- លោក ហុង ហ៊ីម បានបញ្ជាក់ថា នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០ លោករដ្ឋបាលប្រចាំក្រុមហ៊ុនបានហៅលោកទៅប្រាប់ថា នៅផ្នែកអ៊ុតអត់មានការងារធ្វើ ហើយកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ របស់លោកដល់កាលកំណត់ផុតរលត់ហើយ។ ដោយសារកិច្ចសន្យាការងាររបស់លោកដល់កាលកំណត់ ចំពេលអត់ការងារធ្វើបែបនេះ ត្រូវជម្រុះចេញ ដោយមិនដឹងថា ថ្ងៃណាយកចូលវិញទេ។ ភាគីក្រុមហ៊ុនមិនជំទាស់នឹងការលើកឡើងនេះទេ ហើយបន្ថែមថា មូលហេតុដែលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងាររបស់លោក ហុង ហ៊ីម ថា គឺដោយសារអត់ការងារធ្វើ ហើយកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ របស់គាត់ដល់កាលកំណត់ផុតរលត់។
- ភាគីកម្មករនិយោជិតញ្ជាក់ថា នៅផ្នែកអ៊ុតមានកម្មករនិយោជិតសរុបចំនួន ៣០ នាក់។ នៅក្នុងផ្នែកអ៊ុតនេះ មានកម្មករនិយោជិតចំនួនបីនាក់ទៀត ដែលត្រូវដល់កាលកំណត់ផុតរលត់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាដែរ ដែលអ្នកទាំងនេះ ជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ។ ក្រៅពីនេះ ក៏មានកិច្ចសន្យាការងារកម្មករនិយោជិតផ្សេងទៀត ដែលមិនមែនសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ៥ ទៅ ៦ នាក់ ដែលត្រូវបានដល់កាលកំណត់ដែលក្រុមហ៊ុនមិនបានបន្តកិច្ចសន្យាការងារដែរ។
- ភាគីកម្មករនិយោជិតបញ្ជាក់ទៀតថា មានកម្មករនិយោជិតចំនួនបីនាក់ នៅផ្នែកអ៊ុត ក្រុមហ៊ុនបានបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាឱ្យ ហើយអ្នកទាំងនេះមិនមែនជាសមាជិកសហជីពប្រជា

ធិបតេយ្យកម្មករកាត់ដេរ។ ក្រុមហ៊ុនបញ្ជាក់ថា ក្រុមហ៊ុនមិនដឹងពីបញ្ហានេះទេ ព្រោះគាត់ជារដ្ឋបាលថ្មី គាត់ចាំពិនិត្យមើលបញ្ជីសិន ថាតើមានការបន្តនេះ ឬអត់។

- ភាគីក្រុមហ៊ុនបានលើកឡើងថា នៅថ្ងៃតែមួយនៃការដល់កាលកំណត់បញ្ចប់កិច្ចសន្យាការងារជាមួយកម្មករនិយោជិត ហុង ហ៊ីម នេះ មានកម្មករនិយោជិតទាំងអស់ ៨ នាក់ ដែលក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ពេលដល់កាលកំណត់។
- ភាគីក្រុមហ៊ុនលើកឡើងថា លោក ហុង ហ៊ីម បានផ្តិតមេដៃយល់ព្រមនឹងការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ របស់គាត់ហើយ ប៉ុន្តែ ក្រោយមកបែរជាមិនព្រមទទួលប្រាក់បំណាច់កិច្ចសន្យាទៅវិញ។ លោក ហុង ហ៊ីម លើកឡើងថា លោកបានផ្តិតមេដៃមុនរដ្ឋបាលប្រាប់ថា ផ្តិតមេដៃនេះ ដើម្បីបញ្ចប់កិច្ចសន្យាការងារ ទើបក្រោយមក គាត់មិនព្រមយកប្រាក់បំណាច់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា។

**<u>ករណីលោក ជេត ម៉ាន់ :</u>**

- ភាគីកម្មករនិយោជិតបានលើកឡើងថា លោក ជេត ម៉ាន់ ចូលធ្វើការដំបូងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០ មានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែម្តង។ លោកធ្វើការនៅផ្នែកខាត់ ជាកម្មករនិយោជិតធម្មតា ទទួលបានប្រាក់ឈ្នួលសរុបជាមធ្យមទទួលបានពី ១០០ ទៅ ១៦០ ដុល្លារអាមេរិក ក្នុងមួយខែ។ លោកត្រូវបានក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចុងក្រោយនៅ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១០។ ភាគីក្រុមហ៊ុនមិនជំទាស់នឹងការលើកឡើងនេះទេ។
- លោក ជេត ម៉ាន់ បានបញ្ជាក់ថា នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១០ ក្រុមហ៊ុនបានហៅលោកទៅប្រាប់ថា នៅផ្នែកខាត់អត់មានការងារធ្វើ ហើយកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ របស់លោក ដល់កាលកំណត់ហើយ ហេតុនេះលោកត្រូវបញ្ចប់កិច្ចសន្យាការងារ។ នៅពេលនោះ លោកមិនព្រមផ្តិតមេដៃទទួលយកការបញ្ចប់កិច្ចសន្យាការងាររបស់គាត់ទេ ដោយលោកលើកហេតុផលថា អ្នកផ្សេងទៀត ក្រុមហ៊ុនបន្តកិច្ចសន្យាការងារឱ្យ ប៉ុន្តែ និយោជកត្រូវបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់លោកទៅវិញ។
- ក្រុមហ៊ុនបានបញ្ជាក់ថា នៅក្នុងផ្នែកខាត់ដែលលោក ជេត ម៉ាន់ ធ្វើការនេះ មានកម្មករនិយោជិតទាំងអស់ប្រហែល ២០០ នាក់ ក្នុងនោះមានផ្នែកខាត់ពុកមាត់ ខាត់សាច់ ខាត់ប្រហោង និងរ៉ៃ។ ក្រុមហ៊ុនបានបញ្ចប់កិច្ចសន្យាការងារមានកំណត់ថិរវេលា របស់កម្មករនិយោជិត ទាំងអស់ចំនួន ៣០ នាក់ នៅផ្នែកខាត់ទាំងមូលនេះ ក្នុងចំណោមកម្មករនិយោជិតដែលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារទាំងអស់ចំនួន ៣៧ នាក់នោះ។ លើសពីនេះទៀត ក្រុមហ៊ុនបានបញ្ជាក់ទៀតថា នៅថ្ងៃតែមួយ

ជាមួយនឹងការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានេះ មានការមិនបន្តកិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់កម្មករផ្សេងទៀតដែរ ដែលមិនមែនជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ ។ ភាគីកម្មករនិយោជិតមិនជំទាស់នឹងការលើកឡើងនេះទេ ។

- លោក ជេត ម៉ាន់ អះអាងថា លោកធ្វើការក្នុងសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ មានតួនាទីជាទីប្រឹក្សាទី២ ។ លោកបញ្ជាក់ទៀតថា នៅមុនពេលក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ របស់លោក លោកមិនបានធ្វើសកម្មភាពសហជីពអ្វីទេ ។

**ករណីលោក ហួន សុខរ៉ូ :**

- ភាគីកម្មករនិយោជិត និងភាគីនិយោជកលើកឡើងថា លោក ហួន សុខរ៉ូ ចូលធ្វើការដំបូងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១០ ដែលមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែម្តងៗ ។ លោកធ្វើការនៅផ្នែកខាត់ប្រហោង ជាកម្មករនិយោជិតធម្មតា ទទួលបានប្រាក់ឈ្នួលក្នុងខែចុងក្រោយ ប្រហែល ១៥០ ដុល្លារអាមេរិក ។ លោកត្រូវបានក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចុងក្រោយ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១០ ។
- ក្រុមហ៊ុនបញ្ជាក់មូលហេតុនៃការបញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលារបស់លោកថា គឺដោយសារក្រុមហ៊ុនអត់មានការងារឱ្យធ្វើ ។ ចំពោះកំហុសដែលលោក ហួន សុខរ៉ូ បានប្រព្រឹត្តទាក់ទងនឹងការលាក់ខោទុកខាត់តែម្នាក់ឯង មិនចែកឱ្យអ្នកផ្សេងយកមកធ្វើនោះ ក្រុមហ៊ុនមិនចាត់ជាមូលហេតុនៃការមិនបន្តការងារឱ្យគាត់ទេ ។
- ដោយសារសាម៉ីខ្លួនមិនមានវត្តមាននៅក្នុងសវនាការ ភាគីសហជីពបញ្ជាក់ថា មិនដឹងពីអង្គហេតុលំអិតច្បាស់លាស់ទាក់ទងនឹងកម្មករនិយោជិតរូបនេះទេ ។

**ហេតុផលនៃសេចក្តីសម្រេចៈ**

**ចំណុចវិវាទទី១ ទី២ និងទី៣:** ***ភាគីកម្មករនិយោជិតទាមទារ ឱ្យក្រុមហ៊ុនទទួលយកកម្មករនិយោជិតចំនួន ៣ នាក់ ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល និងបញ្ឈប់ការរើសអើង ធ្វើទុក្ខបុកម្នេញមកលើថ្នាក់ដឹកនាំ សកម្មជន និងសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ***

ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកទទួលយកកម្មករនិយោជិតចំនួន ៣ នាក់ ចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល ។ ភាគីនិយោជកមិនព្រមទទួលយកកម្មករនិយោជិតទាំង ៣ នាក់ ចូលធ្វើការវិញទេ ពីព្រោះនិយោជកលើកឡើងថា កិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំង ៣ នាក់ បានដល់កាលកំណត់ហើយ ។

ក្នុងចំណោមកម្មករនិយោជិតទាំង ៣ នាក់ មានកម្មករនិយោជិតមួយរូប ឈ្មោះ **ហួន សុខរ៉ូ** ដែលជាសមាជិករបស់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ តំណាងភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ បានអវត្តមានពេលសវនាការ ដោយសារឈឺមិនអាចមកចូលរួមបាន។ នៅថ្ងៃសវនាការ និងរហូតមកដល់ថ្ងៃចេញសេចក្តីបង្គាប់នេះ ភាគីសហជីពមិនបានបញ្ជូនបញ្ជិកាសហជីព មកក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមការតម្រូវរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ។ ហេតុនេះ មុននឹងក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកត្រូវទទួលយកកម្មករនិយោជិតទាំង ៣ នាក់ ចូលធ្វើការវិញនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាជាមុន អំពីភាពជាតំណាងរបស់សហជីពដែលមិនទាន់មានបញ្ជិកាសម្រាប់ករណីកម្មករនិយោជិត **ហួន សុខរ៉ូ** ដែលមិនបានចូលរួមសវនាការ។

មាត្រា២៦៨ កថាខណ្ឌទី១ និង ទី២ ឆ្នាំ១៩៩៧ ចែងថា "*ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបានសិទ្ធិ និង ផលប្រយោជន៍ទាំងឡាយដែលច្បាប់ការងារនេះទទួលស្គាល់ ស្ថាបនិកនៃអង្គការនេះត្រូវយកលក្ខន្តិកៈ និង បញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និង កិច្ចការរដ្ឋបាល ទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារដើម្បីសុំចុះបញ្ជិកា។ រាល់ការសុំចុះបញ្ជិកាត្រូវភ្ជាប់មានជាមួយនូវកំណត់ហេតុនៃការបង្កើតអង្គការផង។*

*ក្នុងរយៈពេលពីរខែ ក្រោយពីបានទទួលសំណុំបែបបទសុំចុះបញ្ជិកា បើក្រសួងទទួលបន្ទុកវិស័យការងារមិនបានឆ្លើយតប ត្រូវចាត់ទុកអង្គការវិជ្ជាជីវៈនោះ ថាបានចុះបញ្ជិការួចហើយ។...*"

ទាក់ទងនឹងមាត្រាខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រសួងទទួលបន្ទុកវិស័យការងារមានរយៈពេលពីរខែក្នុងការឆ្លើយតបចំពោះសំណើសុំចុះបញ្ជិការបស់អង្គការវិជ្ជាជីវៈ ក្រោយពីទទួលបានសំណុំបែបបទសុំចុះបញ្ជិកា។ បើសិនជាក្នុងរយៈពេលពីរខែនេះ ក្រសួងទទួលបន្ទុកវិស័យការងារមិនឆ្លើយតបចំពោះការស្នើសុំទេ អង្គការវិជ្ជាជីវៈនោះត្រូវបានចាត់ទុកថា ចុះបញ្ជិការួចហើយ។

ផ្អែកតាមភស្តុតាងដែលបញ្ជូនដោយភាគីកម្មករនិយោជិតមកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការបោះឆ្នោតបង្កើតសហជីព គឺធ្វើឡើងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០ ហើយកាលបរិច្ឆេទបង្កាន់ដៃសុំចុះបញ្ជិកាគឺ នៅថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១០។ គិតត្រឹមថ្ងៃសវនាការនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ គឺមានរយៈពេលតិចជាងពីរខែ ដែលក្រសួងទទួលបន្ទុកវិស័យការងារមិនទាន់បានឆ្លើយតបចំពោះសំណើសុំចុះបញ្ជិការបស់សហជីពនេះ។

យោងតាមការបកស្រាយមាត្រា២៦៨ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរមិនទាន់បានចុះបញ្ជិកាទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពដែលមិនទាន់មានបញ្ជិកា មិនអាចតំណាងសមាជិករបស់ខ្លួនបានឡើយ។

ប្រការ១៩ នៃប្រកាស០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ បានចែងថា " *ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាង*

*ដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។"*

តាមរយៈប្រការនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នៅក្នុងសវនាការអាជ្ញាកណ្តាល ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិត **ហួន សុខរ៉ូ** ដែលមិនបានចូលរួមសវនាការ មិនបានធ្វើការអនុញ្ញាតជាលាយលក្ខណ៍អក្សរដល់សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ នៅក្នុងការតំណាងស្របច្បាប់ ឱ្យកម្មករនិយោជិតរូបនេះ នៅក្នុងសំណុំរឿងនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាការទាមទារចំណុចវិវាទនៅក្នុងសំណុំរឿងនេះ តែទៅលើកម្មករនិយោជិតពីររូបទៀតតែប៉ុណ្ណោះ គឺកម្មករនិយោជិត **ហុង ហ៊ីម** និង **ជេត ម៉ាន់**។

ផ្អែកតាមអង្គហេតុ ភាគីកម្មករនិយោជិតបានលើកឡើង និយោជកបញ្ឈប់ពួកគាត់ ដោយសារការរើសអើងសហជីព។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាថា តើនិយោជកបានរើសអើងសហជីពដែរឬទេ នៅក្នុងការបញ្ឈប់កម្មករនិយោជិតទាំង ២ រូបនេះ។

មាត្រា១២ នៃច្បាប់ស្តីពីការងារ ចែងថា *"វៀរលែងតែមានបទប្បញ្ញត្តិនៃច្បាប់ការងារនេះបញ្ជាក់ច្បាស់ ឬ អត្ថបទដទៃទៀតដែលមានលក្ខណៈជាច្បាប់ ឬជាបទបញ្ជាដែលការពារស្ត្រី និងកូនក្មេង ក៏ដូចជាបទប្បបញ្ញត្តិ ... គ្មាននិយោជកណាម្នាក់អាចយកបញ្ហា:*

*...*

*ការចូលជាសមាជិកសហជីពកម្មករនិយោជិត ឬការធ្វើសកម្មភាពក្នុងសហជីព ដើម្បីជាលេសធ្វើសេចក្តីសំរេចអំពី:*

*...*

*វិន័យ ឬការផ្តាច់កិច្ចសន្យាការងារ។"*

មាត្រា២៧៩ នៃច្បាប់ស្តីពីការងារ ចែងថា *"ត្រូវហាមឃាត់ចំពោះនិយោជកគ្រប់រូប មិនឱ្យយកការចូលរួមជាសមាជិករបស់សហជីព ឬការចូលរួមសកម្មភាពរបស់សហជីពនៃកម្មករនិយោជិត ដើម្បីធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសឱ្យចូលធ្វើការងារ ការដឹកនាំ និងការបែងចែងការងារ ការតម្លើងថ្នាក់ ការផ្តល់ប្រាក់ឈ្នួល និងការផ្តល់ផលប្រយោជន៍ វិធានការដាក់វិន័យ និង ការបណ្តេញចេញ។"*

តាមរយៈមាត្រាខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកត្រូវបានហាមឃាត់មិនឱ្យមានការរើសអើង ក្នុងការបន្ត ឬមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិត *(សូមមើលសេចក្តីបង្គាប់អាជ្ញា*

*កណ្តាល លេខ ១៥៥/០៩-ឃូអេសអេ ហេតុផលចំណុចវិវាទទី៧ និងលេខ ១០/០៣-ហ្សាក់ស៊ីនតិច ហេតុផលចំណុច វិវាទទី២*)។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើដែរ គឺនិយោជក មិនត្រូវយកមូលហេតុរើសអើងសហជីពដើម្បីបន្ត ឬមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតនោះទេ។

ទាក់ទងនឹងការចោទប្រកាន់ថា និយោជកមានការរើសអើងសហជីពនោះ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថា ភាគីកម្មករនិយោជិតមានបន្ទុកផ្តល់ភស្តុតាងក្នុងការចោទប្រកាន់ថា និយោជករើសអើងសហជីព *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១១២/០៦-រីវើរិច ចំណុចវិវាទទី១, លេខ ០១/០៧-ស៊ុខព្រីម ហេតុផលចំណុចវិវាទទី១, លេខ ១៤៨/០៧-បាយហ៊ី ហេតុផលចំណុចវិវាទទី១, លេខ ១៥៨/០៨- អ៊ឹម និងវ៉ៃ ទី៤ និងលេខ ៤០/០៩-ហ្គោលហ្វេម ហេតុផលចំណុចវិវាទទី១)* ។

ទាក់ទងនឹងភស្តុតាងនៃការរើសអើងសហជីព ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាលើការឆ្លើយបំភ្លឺនៅក្នុងសវនាការ និងធ្វើការពិនិត្យទៅលើភស្តុតាង ដែលពាក់ព័ន្ធទៅនឹងសំណុំរឿង ដើម្បីកំណត់ថា តើមានការរើសអើងសហជីពកើតមានឡើងទាក់ទងនឹងការបញ្ឈប់កម្មករនិយោជិតដែរ ឬទេ *(សូមមើលសេចក្តីបង្គាប់លេខ ១០/០៩-ញូវ៉ាយដឺ ខេមបូឌា ហេតុផលចំណុចវិវាទទី១ និងទី២, លេខ ១៥៨/០៨-អ៊ឹម និង វ៉ៃ ទី៤ និងលេខ ៤០/០៩-ហ្គោលហ្វេម ហេតុផលចំណុចវិវាទទី១)* ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតបានលើកឡើងថា ភាគីនិយោជកបានរើសអើងសហជីព នៅក្នុងការមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតនេះ។ ភាគីកម្មករនិយោជិតបានបន្ថែមទៀតថា និយោជកបានបន្តកិច្ចសន្យាកម្មករនិយោជិតដទៃទៀត ប៉ុន្តែ មិនបានបន្តកិច្ចសន្យារបស់ពួកគាត់ទេ។ ភាគីនិយោជកបានជំទាស់នឹងការលើកឡើងនេះថា គាត់មិនបានរើសអើងសហជីព សម្រាប់ការមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតនោះទេ។ ភាគីនិយោជកបានបញ្ជាក់ថា និយោជកមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងនេះ ពីព្រោះកិច្ចសន្យាការងារមានកំណត់ថិរវេលារបស់ពួកគាត់ដល់កាលកំណត់។ លើសពីនេះ ភាគីនិយោជកបានបញ្ជាក់មូលហេតុបន្ថែមទៀតថា ក្រុមហ៊ុនមិនមានការងារធ្វើទេ ទើបក្រុមហ៊ុនមិនបន្តកិច្ចសន្យាការងារមានថិរវេលាកំណត់របស់កម្មករនិយោជិត។ ម្យ៉ាងទៀត ភាគីនិយោជកក៏មិនបានបន្តកិច្ចសន្យាការងារ ដែលមានថិរវេលាកំណត់ជាមួយកម្មករនិយោជិតទាំង ៣៧ នាក់ ផ្សេងទៀតផងដែរ។ កម្មករនិយោជិតដទៃទៀត ដែលនិយោជកមិនបានបន្តកិច្ចសន្យាការងារ គឺរួមមានទាំងកម្មករនិយោជិត ដែលជាសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ និងកម្មករនិយោជិតដែលមិនមែនជាសមាជិកនៃសហជីពនេះផងដែរ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា តាមរយៈការឆ្លើយបំភ្លឺនៅក្នុងសវនាការនេះ គឺមិនអាចឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មានការរើសអើងសហជីពកើតឡើងទេ នៅក្នុងការមិនបន្តកិច្ចសន្យាការងាររបស់

កម្មករនិយោជិតទាំងពីររូបនេះទេ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបន្តពិចារណាទៀតថា តើការដែលនិយោជកមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតនេះ បានអនុវត្តត្រឹមត្រូវតាមច្បាប់ស្តីពីការងារដែរ ឬទេ?

មាត្រា ៧៣ នៃច្បាប់ការងារឆ្នាំ១៩៩៧ ចែងថា " *កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ត្រូវផុតរលត់តាមធម្មតានូវពេលដល់កាលកំណត់...*" ។

នៅក្នុងសំណុំរឿងមុន ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា *"ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាត្រូវផុតរលត់ជាស្វ័យប្រវត្តិនៅពេលដល់កាលកំណត់។ មានន័យថា កាតព្វកិច្ចរបស់ភាគីនិយោជក និងកម្មករនិយោជិត ត្រូវបានផុតរលត់។ ដូច្នេះ មិនមែនភាគីណាមួយអាចបង្ខំភាគីមួយទៀតឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀង" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០០/០៧-ហូយៀ ខេមបូឌា ហេតុផលចំណុចវិវាទទី២)* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺកិច្ចសន្យាការងារមានថិរវេលាកំណត់ ត្រូវផុតរលត់ជាស្វ័យប្រវត្តិ នៅពេលដល់កាលកំណត់ ហើយកាតព្វកិច្ចរបស់ភាគីនិយោជក និងកម្មករនិយោជិតត្រូវបានផុតរលត់។ ហេតុនេះហើយ មិនមានភាគីណាមួយ អាចបង្ខំភាគីមួយទៀត ឱ្យបន្តកិច្ចសន្យាទេ ប្រសិនបើគ្មានការព្រមព្រៀង។

មាត្រា ៧៣ កថាខ័ណ្ឌទី៥ នៃច្បាប់ស្តីពីការងារចែងថា *"ប្រសិនបើកិច្ចសន្យាមានកំណត់ថិរវេលាលើសពីប្រាំមួយខែ កម្មករនិយោជិតត្រូវបានគេជូនដំណឹងជាមុន ចំនួនដប់ថ្ងៃអំពីការផុតរលត់នៃកិច្ចសន្យា ឬការមិនបន្តឡើងវិញនៃកិច្ចសន្យា។ រយៈពេលជូនដំណឹងមុននេះ ត្រូវកំណត់ឱ្យដល់ដប់ប្រាំថ្ងៃ ចំពោះកិច្ចសន្យាដែលមានថិរវេលាលើសពីមួយឆ្នាំ។ បើគ្មានការជូនដំណឹងមុនទេ កិច្ចសន្យាត្រូវបន្តក្នុងថិរវេលាស្មើគ្នានឹងថិរវេលា ដែលបានចុះកិច្ចសន្យាគ្រាដំបូង ឬត្រូវចាត់ទុកថា ជាកិច្ចសន្យាគ្មានកំណត់ថិរវេលាពិតប្រាកដ បើថិរវេលា សរុប នៃការបន្តកិច្ចសន្យានោះលើសពីថិរវេលា ដែលមានកំណត់ក្នុងមាត្រា ៦៧"* ។

តាមខ្លឹមសារនៃមាត្រា ៧៣ កថាខណ្ឌទី៥ នៃច្បាប់ស្តីពីការងារខាងលើនេះ មានន័យថា ប្រសិនបើកិច្ចសន្យាការងារមានកំណត់ថិរវេលាតិចជាងរយៈពេល ៦ ខែ គឺមិនចាំបាច់មានការជូនដំណឹងជាមុនទេ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១០៧/០៤-ហ្សាក់ស៊ីនតិច ហេតុផលចំណុចវិវាទទី៤ និងលេខ ៧១/០៩-ហាយថិច ហេតុផលចំណុចវិវាទទី៦)* ។

នៅក្នុងសេក្តីបង្គាប់លេខ ១១៥/០៧-វ៉ាយថិច *ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបដិសេធការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនជូនដំណឹងមុននៅពេលដែលផុតរលត់នៃកិច្ចសន្យាការងារ និងមិនបន្តឡើងវិញនៃកិច្ចសន្យាការងារ ដែលមានថិរវេលាកំណត់តិចជាង ០៦ ខែ (សូមមើលសេចក្តីបង្គាប់លេខ ១១៥/០៧- វ៉ាយថិច ហេតុផលចំណុចវិវាទទី២)"* ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗដែរ គឺកម្មករនិយោជិតទាំង ២ នាក់នេះ មានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា តិចជាង ៦ ខែ។ ដូច្នេះ និយោជកមិនមានកាតព្វកិច្ចត្រូវជូនដំណឹង ទៅកម្មករនិយោជិតអំពីការបញ្ឈប់នេះទេ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកបានគោរពទៅតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ នៅក្នុងការមិនបន្តកិច្ចសន្យាការងាររបស់កម្មករនិយោជិតទាំងពីររូបនេះ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់កម្មកនិយោជិតឱ្យនិយោជកទទួលយកលោក **ហុង ហ៊ឹម** និងលោក **ជេត ម៉ាន់** ចូលធ្វើការវិញ និងឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលដល់ពួកគាត់។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី១ ទី២ និងទី៣:**

- បដិសេធការទាមទាររបស់កម្មកនិយោជិតឱ្យនិយោជក ទទួលយកលោក **ហុង ហ៊ឹម** និងលោក **ជេត ម៉ាន់** ចូលធ្វើការវិញ និងឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលដល់ពួកគាត់។
- បដិសេធការទាមទាររបស់កម្មករនិយោជិត ដែលលើកឡើងថា មានការរើសអើង ធ្វើទុក្ខបុកម្នេញចំពោះថ្នាក់ដឹកនាំ សកម្មជន និងសមាជិកសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរ។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **ម៉ារ សំបូរណា**

ហត្ថលេខា: ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **ឡុន ស៊ីផាន់**

ហត្ថលេខា: ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ម៉ែន ម៉ុនឈយា**

ហត្ថលេខា: ------------------------------------